# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ ១១១៤ សសក/ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០០៩

# ស េ ច ក្តី ស េ្រ ម ច
## ស្តីពី
## ការបង្កើតគណៈកម្មការត្រួតពិនិត្យការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦ /០៦ ចុះថ្ងៃទី២៤ ខែមករាឆ្នាំ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសុខាភិបាល
- បានឃើញលិខិតលេខ ៤៧១៣ អយក.ឧទន ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ របស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមការចាំបាច់របស់ក្រសួង

## ស េ្រ ម ច

**ប្រការ១.**~ត្រូវបានបង្កើតគណៈកម្មការត្រួតពិនិត្យការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈ និង ឯកជន ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម **ឆា ត្រួយ** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | ប្រធាន |
| ២-លោកស្រីឱសថ. **គាត តួង** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស | អនុប្រធាន |
| ៣-លោក **គង់ តុម៉ីកា** | អនុប្រធាននាយកដ្ឋានឧត្តមសិក្សា/ក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៤-លោកវេជ្ជ. **គុំ សំសុង** | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស | សមាជិក |
| ៥-លោកវេជ្ជ. **សុខ ស្រ៊ុន** | អនុប្រធាននាយកដ្ឋានមន្ទីរពេទ្យ | សមាជិក |
| ៦-កញ្ញាវេជ្ជ. **ឌួច សុខនាង** | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស | សមាជិកអចិន្ត្រៃយ៍ |
| ៧-លោកស្រី **រស់ ចាន់សោភា** | នាយកដ្ឋានឧត្តមសិក្សា/ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក ។ |

**ប្រការ២.**~តួនាទីភារៈកិច្ចរបស់គណៈកម្មការត្រួតពិនិត្យ ការបណ្តុះបណ្តាល ក្នុងវិស័យសុខាភិបាល :



ទីស្តីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល,លេខ ១៥១-១៥៣ វុក្ខវិថី កម្ពុជាក្រោម ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៤២៦ ០៣៤/៤២៦ ៨៤១ ទូរស័ព្ទ: (៨៥៥-២៣) ៧២២ ៨៣៣

១- ពិនិត្យវាយតម្លៃលើឯកសារ និង ស្ថានភាពជាក់ស្តែង របស់គ្រឹះស្ថានបណ្តុះបណ្តាល

២- តាមដានវាយតម្លៃ ការអនុវត្តនិយាម នៃការបណ្តុះបណ្តាល ទាំងទ្រឹស្តី និង ការអនុវត្តកម្មសិក្សាគ្លីនិក របស់គ្រឹះស្ថានបណ្តុះបណ្តាល

៣- ធ្វើរបាយការណ៍ អំពីលទ្ធផល ចុះពិនិត្យ វាយតម្លៃ ជូនថ្នាក់ដឹកនាំ ក្រសួងអប់រំ យុវជន និងកីឡា-ក្រសួងសុខាភិបាល ដើម្បីពិនិត្យសម្រេច ។

**ប្រការ៣.-** អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គាធិការក្រសួងសុខាភិបាល ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានមន្ទីរពេទ្យ ព្រមទាំងសាមីខ្លួនដែលមានរាយនាមក្នុងប្រការ១ ត្រូវទទួលភារៈអនុវត្តតាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងអប់រំយុវជន និងកីឡា
- គ្រប់គ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាល
- ដូចប្រការ៣
- ឯកសារ-កាលប្បវត្តិ ៨

ម៉ម_ប៊ុនហេង